# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២០៨.អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលអត្រាពន្ធគយ និងអត្រាអាករពិសេសលើមុខទំនិញមួយចំនួន

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ២៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលអត្រាអាករពិសេសលើទំនិញមួយចំនួន
- បានឃើញ អនុក្រឹត្យលេខ ១៩២ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការកែសម្រួលអត្រាពន្ធគយ និងអត្រាអាករពិសេសលើទំនិញមួយចំនួន
- បានឃើញ អនុក្រឹត្យលេខ ២១០ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលអត្រាពន្ធគយ អត្រាអាករពិសេស និងអត្រាអាករនាំចេញ លើមុខទំនិញមួយចំនួន
- បានឃើញ អនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអត្រាពន្ធគយ អត្រាអាករពិសេស និងអត្រាអាករនាំចេញ លើមុខទំនិញមួយចំនួន

- បានឃើញ អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលអត្រាពន្ធគយ អត្រាអាករពិសេស និងអត្រាអាករនាំចេញ លើមុខទំនិញមួយចំនួន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

## ជំពូក ១

## ការកែសម្រួលអត្រាពន្ធគយលើមុខទំនិញមួយចំនួន

**មាត្រា ១** .- ត្រូវបានបន្ថយអត្រាពន្ធគយលើមុខទំនិញនាំចូលមួយចំនួនដូចខាងក្រោម÷

- **ពី ៧% មក 0%** លើមុខទំនិញវត្ថុធាតុដើមសម្រាប់ផលិតកម្មចំណីអាហារនិងភេសជ្ជៈ និងប្រព័ន្ធសូឡា **ចំនួន ១៣ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ២០១៧ ជាធរមាន ក្នុងទីតាំងរងលេខ÷ ២៨០១.២០.០០
២៩១៦.១៩.០០ ២៩១៨.១៩.០០ ២៩២៤.២៩.១០ ២៩២៩.៩០.១០ ២៩៣៤.៩៩.៩០
៣៣០២.១០.១០ ៣៣០២.១០.២០ ៣៣០២.១០.៩០ ៣៣០២.៩០.០០ ៨៥៤១.៤០.២១
៨៥៤១.៤០.២២ និង ៨៥៤១.៤០.២៩។
- ពី **១៥% មក 0%** លើមុខទំនិញឧបករណ៍ និងគ្រឿងម៉ាស៊ីនកែច្នៃសំខាន់ៗ ដែលបម្រើការដល់សង្វាក់ផលិតកម្មនានា **ចំនួន ៥៦ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ២០១៧ ជាធរមាន ក្នុងទីតាំងរងលេខ÷
៨៤១៩.៣២.១០ ៨៤១៩.៣២.២០ ៨៤២៣.២០.១០ ៨៤២៣.២០.២០ ៨៤២៣.៣០.១០
៨៤២៣.៣០.២០ ៨៤៣៤.១០.១០ ៨៤៣៤.១០.២០ ៨៤៣៤.២០.១០ ៨៤៣៤.២០.២០
៨៤៣៧.៨០.៣០ ៨៤៣៧.៨០.៤០ ៨៤៣៨.៨០.១១ ៨៤៣៨.៨០.១២ ៨៤៣៨.៩០.១២
៨៤៣៨.៩០.២២ ៨៤៣៩.១០.០០ ៨៤៣៩.២០.០០ ៨៤៣៩.៣០.០០ ៨៤៣៩.៩១.០០
៨៤៣៩.៩៩.០០ ៨៤៥៣.១០.១០ ៨៤៥៣.១០.២០ ៨៤៥៣.២០.១០ ៨៤៥៣.២០.២០
៨៤៥៣.៨០.១០ ៨៤៥៣.៨០.២០ ៨៤៥៣.៩០.០០ ៨៤៥៥.១០.០០ ៨៤៥៥.២១.០០
៨៤៥៥.២២.០០ ៨៤៥៥.៣០.០០ ៨៤៧៧.១០.១០ ៨៤៧៧.១០.៣១ ៨៤៧៧.១០.៣៩
៨៤៧៧.២០.១០ ៨៤៧៧.២០.២០ ៨៤៧៧.៣០.០០ ៨៤៧៧.៤០.១០ ៨៤៧៧.៤០.២០
៨៤៧៧.៥១.០០ ៨៤៧៧.៥៩.១០ ៨៤៧៧.៥៩.២០ ៨៤៧៧.៨០.១០ ៨៤៧៧.៨០.២០
៨៤៧៧.៨០.៣១ ៨៤៧៧.៨០.៣៩ ៨៤៧៧.៨០.៤០ ៨៤៧៩.៨២.១០ ៨៤៧៩.៨២.២០
៩០២៧.២០.១០ ៩០២៧.៣០.១០ ៩០២៧.៥០.១០ ៩០២៧.៨០.១០ ៩០២៧.៨០.៣០
និង ៩០២៧.៨០.៤០ ។
- ពី **១៥% មក ៧%** លើមុខទំនិញវត្ថុធាតុដើម និងម៉ាស៊ីនកែច្នៃសំខាន់ៗ បម្រើការឱ្យសង្វាក់ផលិតកម្មនានា **ចំនួន ៦០ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ២០១៧ ជាធរមាន ក្នុងទីតាំងរងលេខ÷ ១៣០២.៣៩.១១
១៣០២.៣៩.១២ ១៣០២.៣៩.១៣ ១៣០២.៣៩.១៩ ៧៣២៦.១១.០០ ៧៣២៦.២០.៥០
៧៣២៦.២០.៦០ ៧៣២៦.៩០.២០ ៨៤២២.១១.០០ ៨៤២២.១៩.០០ ៨៤២២.២០.០០
៨៤២២.៣០.០០ ៨៤២២.៤០.០០ ៨៤៣៥.១០.១០ ៨៤៣៥.១០.២០ ៨៤៣៥.៩០.១០
៨៤៣៥.៩០.២០ ៨៤៦០.១២.០០ ៨៤៦០.១៩.០០ ៨៤៦០.២២.០០ ៨៤៦០.២៣.០០